# សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជឿជាក់ថាដៃគូភេទដូចគ្នានៅកម្ពុជានឹងអាចរៀបការស្របតាមច្បាប់ឆាប់ៗ

**ដោយ៖ សហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់), ១០ កុម្ភៈ ២០២៣** ❤️ 🧡 💛 💚 💙 💜

សហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់) ពិតជាមានសេចក្ដីរីករាយ ដែលអ្នកជំនាញឯករាជ្យរបស់អង្គការ សហប្រជាជាតិទទួលបន្ទុកកិច្ចការពារប្រឆាំងអំពើហិង្សា និងការរើសអើងដោយផ្អែកលើនិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ឬ IE SOGI បានបង្ហាញនៅក្នុងសេចក្ដីសន្និដ្ឋាននៃទស្សនកិច្ចនៅប្រទេសកម្ពុជា អំពីសារៈសំខាន់នៃ *«ការទទួលស្គាល់ដោយច្បាប់ចំពោះគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នាគឺជាគន្លឹះនៃសមាហរណកម្មក្នុងសង្គម»*។

ការរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់សម្រាប់ដៃគូភេទដូចគ្នា គឺជាសេចក្ដីត្រូវការអាទិភាពមួយរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។ សេចក្ដីត្រូវការនេះបានទទួលការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការទទួលយកអនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (UPR)ជុំទី៣ នៅឆ្នាំ២០១៩ របស់អង្គការសហប្រជាជាតិ។ ក្ដីសង្ឃឹមរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាកាន់តែមុតមាំ នៅពេលរាជរដ្ឋាភិបាលកម្ពុជា និងអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិ បង្ហាញនូវការយកចិត្តទុកដាក់ខ្ពស់លើសារៈសំខាន់នៃច្បាប់ទទួលស្គាល់ការរៀបការគូស្រករ និងការពារគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា។ រ៉ក់មានការកោតសរសើរ ដែលIE SOGI បានជួបពិភាក្សាជាមួយអាជ្ញាធររាជរដ្ឋាភិបាលកម្ពុជា ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ឪពុកម្ដាយ ព្រមទាំងសមាជិកក្រុមគ្រួសារ ធ្វើឲ្យទស្សនកិច្ចផ្លូវការនេះទទួលបានព័ត៌មាន គ្រប់ជ្រុងជ្រោយ អំពីស្ថានភាព តម្រូវការ តួនាទី ទំនួលខុសត្រូវ ធនធានៈ និងកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់ការគោរព និងការពារសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅប្រទេសកម្ពុជា។




សេចក្ដីស្នេហា គឺជានិស្ស័យធម្មជាតិនៃបេះដូងរបស់មនុស្សលោក។ មនុស្សពេញវ័យពីរនាក់មានមនោសញ្ចេតនាស្នេហាចំពោះគ្នា ប្ដេជ្ញាចិត្តចាប់ដៃគ្នារួមរស់ជាមួយគ្នា ផ្ដត់ផ្ដង់ជីវភាព ហើយមើលថែគ្នាគ្រប់កាលៈទេសៈ ទាំងពេលលំបាក ពេលធូរធារ ពេលក្រ ពេលមាន ពេលឈឺ ពេលជា ពេលក្មេង និងពេលចាស់ជរា។ ទោះក្នុងស្ថានភាពណាក៏ដោយ ដៃគូជីវិត គឺជាអ្នកដែលយើងហៅរក ពឹងពាក់ និងរង់ចាំមុនគេ។ ទាំងនេះគឺជាគុណតម្លៃនៃសេចក្ដីស្នេហា ជីវិតគូស្រករ និងគ្រួសារនៅក្នុងវប្បធម៌ប្រពៃណីខ្មែរ និងសកលលោក។

ពុកយន់ ម៉ែអៀង គឺជាដៃគូភេទដូចគ្នា នៅខេត្តតាកែវ តស៊ូរួមរស់ជាមួយគ្នារយៈពេល៤០ឆ្នាំ តាំងពីឆ្នាំ១៩៧៩ ហើយបាចិញ្ចឹមកូន៥នាក់តាំងពីនៅតូចៗ។ គាត់ទាំងអស់គ្នាបានបង្រៀនយើងពីភាពស្រស់ស្អាត តម្លៃ និងសារៈសំខាន់នៃសេចក្តីស្នេហា ជីវិតគូស្រករ គ្រួសារ ភាពជាឪពុកម្តាយ និងកូនចៅ ទោះមានតួនាទី មុខងារ និងឋានៈសង្គមបែបណាក៏ដោយ។

ពុកមានប្រសាសន៍ថា *«ពុកនិងម៉ែបានចិញ្ចឹមបីបាច់ ទំនុកបំរុងអាហារហូបចុក ការរៀនសូត្រ អប់រំទូន្មាន រៀបចំគូស្រករដល់កូនទាំង៥នាក់ ហើយជ្រោមជ្រែងពួកគេឲ្យមានការងារនិងមុខរបរ។ ប៉ុន្តែសៀវភៅគ្រួសារមិនបានបញ្ជាក់ថាយើងជាឪពុកម្តាយនិងកូនទេ។ វាជារឿងដែលឈឺចាប់ ហើយភ័យខ្លាច ដែលក្តីស្រឡាញ់ដ៏ស្មោះស ការលះបង់ ថែរក្សា ការពារ និងទំនុកបម្រុងកូនចៅគ្រប់បែបយ៉ាងក្នុងភាពជាឪពុកម្តាយនិងកូនចៅ មិនបានទទួលស្គាល់ដោយឯកសារផ្លូវច្បាប់ ៕»*



បងនី ដែលជាកូនប្រុសម្នាក់របស់ពុកយន់ និងម៉ែអៀង បានលើកឡើងថា *«ប៉ានិងម៉ែមានទឹកចិត្តស្រឡាញ់ និងព្រហ្មវិហារធម៌យ៉ាងធំធេងចំពោះពួកខ្ញុំជាកូន។ លោកទាំងពីរតែងតែយកចិត្តទុកដាក់ ទំនុកបម្រុងពួកខ្ញុំសព្វគ្រប់បែបយ៉ាង ទោះបីជាពេលនេះពួកខ្ញុំមានគ្រួសារហើយក៏ដោយ។ ខ្ញុំមានសំណាងណាស់ដែលមានលោកទាំងពីរជាឪពុកម្តាយ! ជាឪពុកម្តាយដែលជាអ្នកស្រឡាញ់ភេទដូចគ្នា! ពួកខ្ញុំបារម្ភណាស់ដោយសារតែលូវគាត់កាន់តែចាស់ ហើយសុខភាពកាន់តែខ្សោយ។ ខ្ញុំនិងកូនចៅដទៃទៀតក៏ព្យាយាមមើលថែ និងយកចិត្តទុកដាក់ចំពោះគាត់ដែរ។ គ្រួសារពិតជាសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា ៕»*

សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជាទទូចដល់រាជរដ្ឋាភិបាល អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិ ភ្នាក់ងារអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធដទៃទៀត ធ្វើការរួមគ្នាឆ្លើយតប និងបំពេញនូវតម្រូវការមនុស្សជាតិដ៏សាមញ្ញ និងមូលដ្ឋានមួយនេះ ដែលជាការប្តេជ្ញាចិត្តការអនុវត្តអនុសាសន៍ UPR ជុំទី៣ នៅត្រឹមឆ្នាំ២០២៤ ដើម្បីទទួលបានសិទ្ធិរៀបការស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ គូស្រករ និងគ្រួសារដែលមានច្បាប់ការពារពេញលេញ គឺកាន់តែធ្វើឲ្យមានសេចក្តីសុខ សុភមង្គល និងភាពរីកចម្រើន។ លើសពីនេះ ការទទួលស្គាល់អាពាហ៍ពិពាហ៍ និងគ្រួសារភេទដូចគ្នាស្របតាមច្បាប់ គឺជាគន្លឹះនៃការកាត់បន្ថយការរើសអើងនៅក្នុងសហគមន៍ និងសង្គមផងដែរ។ គ្រួសារមានភាពកក់ក្តៅ និងរឹងមាំ សហគមន៍ និងសង្គមជាតិក៏មានភាពសុខដុម និងការអភិវឌ្ឍន៍៕